## ព័ត៌មានបន្ថែម

សំរាប់ព័ត៌មានបន្ថែមស្តីអំពីសេវាកម្មផ្សេងៗរបស់ DPSS, សូមទៅទស្សនាគេហទំព័ររបស់យើង -

**dpss.lacounty.gov**

ដើម្បីដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ សូមចូលទៅគេហទំព័រ
**BenefitsCal.com**

## ការធ្វើពាក្យបណ្តឹងតវ៉ា

បើសិនជាអ្នកជឿជាក់ថា អ្នកមិនបានទទួលកិច្ច ការជំនួយដែលអ្នកត្រូវការនោះទេអ្នកអាចដាក់ពាក្យបណ្តឹងបាន ។ អ្នកក៏អាចដាក់ពាក្យបណ្តឹងមួយបាន បើសិនជា អ្នកមានអារម្មណ៍ថាអ្នកត្រូវ បានរើសអើងពីព្រោះតែភាពពិការនោះ ។

ពាក្យបណ្តឹងតវ៉ារបស់អ្នក អាចត្រូវបានដាក់ប្តឹង ដោយទៅជួបគេដោយផ្ទាល់ឬជាលាយលក្ខណ៍អក្សរតាម (ប្រៃសណីយ៍ ឬអ៊ីម៉ែល) ឬដោយទូរស័ព្ទទៅលេខខាងក្រោម:

Civil Rights Section
12860 Crossroads Parkway South
City of Industry, CA 91746
Phone: (844) 586-5550
TTY: (877) 735-2929
ADAHelp@dpss.lacounty.gov

ខោនធីឡូសអិនយឺឡេស
ក្រសួង
សង្គមកិច្ចសាធារណៈ
(DPSS)

# តើអ្នកត្រូវការឱ្យគេជួយបំរើកិច្ចការដែរឬទេ?

# សិទ្ធិសំរាប់មនុស្សដែលពិការ

ADA-PUB3 - CAMBODIAN

# មិនមែនភាពពិការទាំងអស់ អាចមើលឃើញបានទេ

## តើអ្នកត្រូវការឱ្យគេជួយបំរើកិច្ចការពីព្រោះតែ ពិការភាពឬ?

ច្បាប់ការពារដល់មនុស្សដែលពិការផ្នែករាងកាយ ផ្នែកសតិអារម្មណ៍និងមនុស្សពិការរាងកាយនិងផ្លូវចិត្ត ព្រមទាំងមនុស្សដទៃៗទៀតដែលមានបញ្ហាសុខភាពដ៏ធ្ងន់ធ្ងរផងដែរ ។

តើអ្នកមានពិការភាព ដែលធ្វើឱ្យមានការពិបាកសម្រាប់អ្នក ក្នុងការដាក់ពាក្យស្នើសុំប្រយោជន៍ជំនួយ
ឬ ធ្វើតាមសេចក្តីតម្រូវនៃកម្មវិធីដែរឬទេ? យើងអាចផ្តល់ជូនអ្នកនូវជំនួយបន្ថែម ។ អ្នកមិនចាំបាច់ផ្តល់ឱ្យយើងនូវសំបុត្រពេទ្យ/ភស្តុតាងបញ្ជាក់អំពីស្ថាន
ភាពសុខភាពរបស់អ្នកឡើយ ។
យើងអាចជួយអ្នកជាមួយនឹង:

- ការអានឯកសារ និងសំណេរបស់ យើង
- ការបំពេញសំណេរបស់យើង
- ការទៅយកឯកសារនានាដែលយើងត្រូវការ
- ការផ្លាស់ប្តូរវិធាននៃកម្មវិធីនិងសេចក្តីតម្រូវនៃការងារ
- ការស្នើសុំពេលណាត់ជួប
- ការកែសម្រួលផ្សេងៗទៀតដែលសមហេតុផល

## ភាពពិការទាំងអស់ ប្រហែលជាអាចរួមទាំងបញ្ហាកង្វះសមត្ថភាពជាមួយនឹង:

- ការដើរ អង្គុយ ឬឈរ
- ការអាន ការរៀន ឬការយល់ដឹង
- ការនិយាយ ការស្តាប់ ឬការមើលឃើញ
- ការស្ថិតនៅក្នុងចំណោមហ្វូងមនុស្សជាច្រើន
- ការបាត់បង់ស្មារតីចងចាំ
- ដំណោះស្រាយបញ្ហាផ្លូវចិត្ត



## ការស្នើសុំការកែសម្រួលដែលសមហេតុផល

ដើម្បីស្នើសុំការកែសម្រួលដែលសមហេតុផល អ្នកអាច:

1. សួរទៅបុគ្គលិក DPSS ណាម្នាក់ ឬ
2. ទូរស័ព្ទទៅលេខពិសេសផ្នែក ADA (844) 586-5550, ឬ
3. ទូរស័ព្ទទៅលេខមជ្ឈមណ្ឌលសេវាកិច្ចការអតិថិជនលេខ (866) 613-3777:
   - ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ចាប់ផ្តើមពីម៉ោង 7:30 ព្រឹក ដល់ម៉ោង 6:30 ល្ងាច

   មនុស្សដែលមានភាពអន់ខ្សោយផ្នែកនិយាយស្តីឬថ្លង់ ស្តាប់មិនឮ អាចប្រើឧបករណ៍ TTY តាមទូរស័ព្ទលេខ (877) 735-2929 (ការបញ្ជូនសារបន្តតាមទូរស័ព្ទនៃរដ្ឋកាលីហ្វ័រនីញ៉ា)
4. ស្នើសុំការកែសម្រួលដែលសមហេតុផ ជាលាយលក្ខណ៍អក្សរ ហើយ ផ្ញើទៅ:

   DPSS ADA Title II Coordinato
   12860 Crossroads Parkway South
   City of Industry, CA 91746

   **ឬ ផ្ញើទូរសារ ទៅ:** (562) 692-2240
   **ឬ ផ្ញើអ៊ីម៉ែល ទៅ:**

   ADAHelp@dpss.lacounty.gov

   ការស្នើសុំលើការកែសម្រួលដែលសមហេតុផលភាគច្រើននឹងត្រូវផ្តល់ជូននៅពេលស្នើសុំប៉ុន្តែការស្នើសុំលើសេចក្តី
   ត្រូវការមួយចំនួន ប្រហែលជាត្រូវប្រើពេលប្រាំ(5) ថ្ងៃធ្វើការដើម្បីធ្វើការប៉ា
   ន់ប្រមាណ និង រៀបចំសម្របសម្រួល ។

ADA-PUB3 Rev. 12/22 CAMBODIAN